# កាលនោះ ...

# បដិវត្តន៍មួយ!

ប្រែសំរួលដោយ ប៉ាន.សុធី



ផក អកវែល

យើងសូមថ្លែងអំណរគុណចំពោះ

លោក **អ៊ុច ភិរម្យ**

ដែលបានចែកចាយសៀវភៅនេះដើម្បី

ជូនដល់បងប្អូនរួមជាតិបានអាននៅថ្វីដៃអក្សរសាស្ត្រខ្មែរ



***Perom Uch***

Founder Buddhi Khmer Center

http://www.ibuddhi.org

P.O. Box 111296

Campbell, CA 95011

USA

*In kind appreciation to*

*Mr. Perom Uch*

*for making this book available*

*for all to enjoy Khmer literature.*

# ឧទ្ទិសកថា

ដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការ និង ការស្នើសុំរបស់មិត្តភ័ក្រ្តជាច្រើន ដែលធ្លាប់បានមើលសៀវភៅ **កាលនោះបដិវត្ត** របស់លោក **ផាន សុធី** យើងខ្ញុំជាក្រុមគ្រួសារខំស្រាវជ្រាវរកឃើញហើយបានសម្រេចចិត្តបោះពុម្ពសៀវភៅនេះឡើងវិញ ចំនួន ៥០០ ក្បាល ។

សូមផ្សាយផលានិសង្សដែលកើតពីចិត្តជ្រះថ្លា និងពីការដឹងគុណនេះ ដល់បុព្វការីជនទាំងឡាយ មានមាតាបិតានិងញាតិការ ៧ សន្តាន ព្រមទាំងសព្វសត្វទាំងឡាយក្នុងអនន្តចក្រវាឡតូច ធំ ទាំងអស់ សូមមកអនុមោទនាយកផលានិសង្សនេះ ហើយសូមអោយបានប្រកបដោយសម្បត្តិទាំងបីប្រការ គឺសម្បត្តិមនុស្សមួយ សម្បត្តិទេវតាមួយ និងសម្បត្តិព្រះនិព្វានមួយ ។ សម្បត្តិទាំងបីប្រការនេះ បើអស់លោកប្រាថ្នានូវសម្បត្តិណាមួយ សូមអោយបានសម្រេចតាមចិត្តប្រាថ្នាយារបស់អស់លោកទាំងឡាយនោះ កុំបីឃ្លៀងឃ្លាតឡើយ ។

*ថ្ងៃ ៨ រោច ខែ អាសាឍ ពុទ្ធសករាជ ២៥៤០*

## “ កាលនោះ... បដិវត្តន៍មួយ ! ”

រឿង ANIMAL FARM ជារឿងព្រេងប្រឌិតឡើងនៅក្នុងស្រុកស្រែនៃប្រទេសអង់គ្លេស ។ ឈ្មោះភូមិ - ស្រុក - សត្វ - មនុស្ស ជាឈ្មោះអង់គ្លេស ។ រីឯគំនិត ទំនៀមទម្លាប់ ក៏ស្រង់ចេញពីជនជាតិអង់គ្លេសដែរ ។

ក្នុងការប្រែបកជាភាសាខ្មែរ អ្នកប្រែបានសម្រួលឈ្មោះនិងទំនៀមទម្លាប់ជាខ្មែរ ដើម្បីឲ្យស្រួលអាន ស្រួលថា ស្រួលយល់ ។ ចំពោះគោលគំនិតនិងពាក្យពេចន៍ អ្នកប្រែខំប្រឹងរិះរកមធ្យោបាយគ្រប់បែបយ៉ាង ដើម្បីរក្សាទុកលំនាំដើមឲ្យបានប្រសើរបំផុត ។

អ្នកប្រែសូមឆ្លៀតឱកាសនេះ ដើម្បីថ្លែងអំណរគុណដល់សមាជិកនៃ “សមាគមខ្មែរ អ្នកបកប្រែ និង និពន្ធ” ដែលបានជួយឧបត្ថម្ភគ្រប់បែបយ៉ាង ដើម្បីឲ្យសៀវភៅនេះបានសម្រេច ។

**ប៉ាន សុធី**

ភ្នំពេញ ថ្ងៃទី ១៣ ឧសភា ១៩៧២

# បញ្ចាំងរឿង

មនុស្សចូលពេញរោង ៗ គេអង្គុយស្ងៀម តែអន្ទះអន្ទែងចង់ឃើញអាថ៌កំបាំងនៅពីក្រោយផ្ទាំងសំពត់ពណ៌ក្រហម ។

ទស្សនិកជនទះដៃហ៊ោ ព្រោះល្ខោនចាប់លេងហើយ . . . មួយរំពេចគេឃើញសត្វក្នុងភូមិមួយបបួលគ្នាធ្វើមីទីងយ៉ាងសម្ងាត់ក្នុងជង្រុកធំមួយ ។ ឆ្លៀតពេលដែលចៅហ្វាយមិននៅ វាទាំងអស់នាំគ្នាបញ្ចេញកំហឹង ការឈឺចាប់ វេទនា ស្រេកឃ្លាន ។ មនុស្សជាសត្រូវរបស់វា ។ ដេញមនុស្សឲ្យផុតពីភូមិ គឺជាការរំដោះខ្លួនពីទុក្ខវេទនា ។ ដេញមនុស្សឲ្យផុតពីភូមិ គឺជាសេចក្ដីសង្ឃឹមលើសង្គមថ្មី ជីវិតថ្មី ។ វានាំគ្នាធ្វើបដិវត្តន៍ ។

បដិវត្តន៍បានសម្រេចដូចបំណង ។ គេឃើញវាសប្បាយ ស្រែកហ៊ោកញ្ជ្រៀវ ដើម្បីទទួលជីវិតថ្មី ដែលវាហៅថា “សេរីភាព” ។ ចម្រៀងបដិវត្តន៍ក៏លាន់រំពងឡើងពេញផ្ទៃរោង ។

វាច្រៀងគ្រប់ពេល គ្រប់ទីកន្លែង ។ ក្នុងពេលធ្វើការក៏ដូចជាក្នុងពេលសម្រាក ចម្រៀងបដិវត្តមិនដែលដាច់ពីបបូរមាត់វាឡើយ ។

ពេលវេលាចេះតែកន្លងទៅ. . . បដិវត្តន៍ក៏វិលវល់ ជួនកាលមានសេចក្ដីសង្ឃឹម ជួនកាលអស់ មាន អស់ អស់ មាន ច្របូកច្របល់ក្នុងគំនិត ក្នុងចិត្ត ក្នុងកំហឹង ក្នុងការសរសើរ ក្នុងការសប្បាយ ក្នុងទុក្ខ ក្នុងសុខ វិលវល់ច្របូកច្របល់ពីឆាកមួយទៅឆាកមួយ ។

រាំងននលើកដាក់ ។ ឆាកលំអក៏ផ្លាស់ប្តូរបន្តបន្ទាប់គ្នា ។ ចម្រៀងបដិវត្តន៍ឮស្ងួរកាន់តែតិចទៅៗ លុះគ្រាតែបាត់ស្ងាត់ស្ងៀមឈឹងនៅពេលដែលមនុស្សក្នុងរោងនាំគ្នាដើរចេញម្តងមួយ ៗ ដោយឥតចេញស្តីអ្វីសោះ. . .

" ANIMAL FARM " ជារឿងប្រឌិតឡើងដោយគំនិតមនុស្ស ។ ANIMAL FARM ជារឿងដែលកើតឡើងនៅគ្រប់ទីកន្លែង គ្រប់កាលសម័យ គ្រប់សង្គម គ្រប់ប្រទេស ។ ដូច្នេះ " ANIMAL FARM " ជារឿងព្រេងផង ជារឿងពិតផង ។ ហើយបើនិយាយឲ្យខ្លីទៅ " ANIMAL FARM " ជារឿងនៃជីវិត ។



## ចំពូក ១

*ភូមិ " សម្រែង " ជាកម្មសិទ្ធិផ្តាច់មុខរបស់លោក " ស្មិត " ដែលជាមហាសេដ្ឋីម្នាក់យ៉ាងស្តុកស្តម្ភ ។*

*ល្ងាចនេះ ដោយត្រូវស្រាខ្លាំងពេក គាត់បានបិទទ្វារទ្រុងមាន់ដោយភ្លេចបិទប្រហោងសម្រាប់ឡបាយ ។ គាត់ដើរកាត់ទីធ្លាកាន់គោមគ្រវីគ្រវាត់ យកជើងធាក់ទ្វារក្រោយដោយប៉ះលើយ ។ គាត់អកស្រាមួយកែវទៀតជាបង្ហើយ រួចប្រះខ្លួនលើគ្រែគេងដិតប្រពន្ធដែលកំពុងស្រមុកយ៉ាងស្រងល់ ។*

*ភ្លើងផ្ទះរលត់ តែសភាពស្ងប់ស្ងាត់នៃរាត្រីបានត្រូវរលាយដោយសម្លេងអ៊ូអរចេញពីក្រោលសត្វ ។ តាំងពីព្រលឹមមក មានពាក្យចចាមអារ៉ាមលេចឡើងថា អា " គំនិត " ជ្រូកឈ្មោលដែលជាចាស់ទុំជាងគេក្នុងបណ្តាសត្វទាំងអស់ ចង់រ៉ាយរ៉ាប់ប្រាប់សត្វទាំងឡាយនៅក្នុងក្រោល អំពីយល់សប្តិដ៏ចំឡែករបស់វាកាលពីយប់មិញ ។ គេបានសន្យាថានឹងមកជួបជុំគ្នាក្នុងជង្រុកធំមួយក្នុងពេលដែលចៅហ្វាយគេមិននៅ ។*

*សត្វទាំងអស់ដែលរស់នៅក្នុងក្រោល តែងគោរពអា*

“គំនិត” ហើយត្រៀមខ្លួនជាស្រេចដើម្បីនឹងមកស្តាប់មេដឹកនាំរបស់ពួកគេ ថ្វីបើត្រូវខានដេកក៏ដោយ ។

នៅចុងខាងណោះ គេឃើញអា “គំនិត” ដេកចាំជាស្រេចនៅលើគ្រែចំបើងដែលវានឹងយកជាវេទិកា ។ នៅពីមុខមានគោមមួយព្យួរជាប់នឹងធ្នឹមសម្រាប់បំភ្លឺ ។

អា “គំនិត” អាយុ ១២ ឆ្នាំ ។ វាមានរាងធាត់ស្លៀចតែនៅរក្សារាងរៅហាក់ដូចជាស្តេចជ្រូក មានមុខមាត់ ហាក់ដូចជាអ្នកចេះដឹង ថ្វីបើនៅមាត់វាមានចង្កូមលៀនចេញមកក៏ដោយ ។

សត្វទាំងឡាយនាំគ្នាចូលមកក្នុងជង្រុកជាបន្តៗគ្នា ហើយរកកន្លែងអង្គុយរៀងៗខ្លួន ។ អ្នកដែលមកដល់មុនគេគឺមី “ព្រុះ” មី “ម្រេច” និងមី “ល្មុង” ជាឆ្កែនិងជាពួកជ្រូកដែលចូលទៅអង្គុយនៅមុខវេទិកា ។ ពួកមាន់នាំគ្នាទំលើធ្នឹមបង្អួច ចំណែកឯពួកព្រាបនាំគ្នាទទះស្លាបនៅលើផ្លោង ។ ចៀមនិងគោទំរេតខ្លួន ហើយទំពាអៀងនៅពីក្រោយពួកជ្រូក ។ សេះពីរសម្រាប់អូសរទេះគឺអា “ព្រញ” និងមី “កណ្តូបសេះ” បោះជំហានមួយៗដើរចូលមកដាក់ជើងថ្នមៗខ្លាចក្រែងមានសត្វល្អិតនៅបង្កប់ខ្លួនក្នុងគំនរចំបើង ។ មី “កណ្តូបសេះ” ជាសេះញី ចូលវ័យកណ្តាលហើយ នៅ



មានរាងស្គមនៅឡើយ ក្រោយពីបានសម្រាលកូនទី ៤ ទើបនឹងរួចថ្មីៗនេះ ។ អា “ព្រញ” មានមាឌខាំខ្ពស់ជំបងប្រហែល ២ ម៉ែត មានកម្លាំងលើសពីសេះធម្មតា ។ មានឆ្នូតសនៅចុងច្រមុះ ធ្វើឱ្យវាមានមុខភ្លើ ។ តាមពិតវាក៏មិនមែនជាសត្វឆ្លាតដែរ ។ គេទាំងឡាយ តែងកោតសរសើរវាថាជាសត្វអង់អាចហើយមានកម្លាំង ។ បន្ទាប់ពីសេះ គឺពពែឈ្មោះមី “ភ្ញុក” និងអា “ភ្លើ” ។ អាភ្លើចាស់ជាងគេឆាប់ខឹងជាងសត្វទាំងអស់នៅក្នុងភូមិ ។ វានិយាយតិច ។ តែកាលណាវានិយាយម្តងៗ វាច្រើនបញ្ចិតបញ្ចៀងឱ្យគេឯង ។ ដូចជាវាតែងនិយាយថា ព្រះបានប្រទានកន្ទុយឱ្យវាសម្រាប់បង្ការរុយ តែកាលណាកន្ទុយវាជ្រុះអស់ទៅ រុយក៏មុខតែស្លាប់អស់ដែរ ។ វាមិនដែលសើចទេ ហើយបើកាលណាគេសួរ ដេញដោលវាថាមកពីហេតុអ្វី វាឆ្លើយថាគ្មានអ្វីដែលត្រូវសើចសោះក្នុងលោកនេះ ។ តាមពិតទៅ វាជាសម្លាញ់អាព្រញ ព្រោះគេតែងឃើញវាទាំងពីរនេះស៊ីស្មៅជាមួយគ្នាថ្វីបើវាមិនដែលនិយាយរកគ្នាមួយម៉ាត់សោះនោះក៏ដោយ ។ គ្រាន់តែសេះពីរនេះប្រុះដេកក្លាម ស្រាប់តែមានកូនទាមួយហ្វូង ដែលទើបនឹងស្លាប់មេ រត់ស្រូចូលមក ហើយរទឹសទទាសរកកន្លែងស្រឡះ សម្រាប់អង្គុយ ដូចជាខ្លាច

គេផាន់ ។ វាចូលទៅសម្ងំនៅចំចន្លោះជើងទាំងពីររបស់មី "កណ្តូបសេះ" ។ លុះដាក់ខ្លួនស្រប៉ាប់លើដីហើយ កូនទាទាំងនោះក៏ធ្មេចភ្នែកដេកលក់ទាំងអស់គ្នាទៅ ។

បន្ទាប់មកទៀតគឺ មី "ប្រផេះ" មេសេះត្លើហើយចោត ដែលពូ "ស្វិត" ទុកសម្រាប់ប្រើដើម្បីផ្ទុកអីវ៉ាន់និងសម្ភារៈ ។ វាបោះជំហានមួយៗ ដើរចូលមកដោយស្ទាត់ស្ទៀម ទំពាស្មៅមួយដុំនៅក្នុងមាត់ ។ វាចូលទៅជិតមុខវេទិកាដើម្បីបង្ហាញបូក្រហម ដែលចងជាប់នៅនឹងកវា ។

ចូលមកដល់ក្រោយគេគឺឆ្មា ។ វាដើរចុះដើរឡើងដើម្បីរកកន្លែងកក់ក្តៅ ។ ទីបំផុតវាបានប្រជ្រៀតខ្លួនដេកចន្លោះអា "ព្រួញ" និងមី "កណ្តូបសេះ" ។ វាដេកហើយស្រមុករហូត គ្មានបានស្តាប់អា "គំនិត" មួយម៉ាត់ឡើយ ។

សត្វទាំងអស់មកដល់ហើយលើកលែងតែអា "ខ្វក" ដែលជាក្អែកសាំង ។ វាទំធ្មេចភ្នែកលក់លើបង្គង់ក្រោយទ្វារ ។ ក្រោយពីបានសង្កេតឃើញថាសត្វទាំងអស់រកកន្លែងស្រួលបួល និង រៀបចំខ្លួនប្រាណចាំស្តាប់ហើយអា "គំនិត" ក៏ហែមបន្ទរបំពង់ក ហើយក៏ចាប់ផ្តើមនិយាយដូចតទៅ ៖

សមមិត្តទាំងអស់គ្នាបានដឹងហើយថាពីយប់មិញ អញបានយល់សប្តិយ៉ាងចម្លែក ។ តែល្អើយចាំអញនិយាយរឿង



យល់សប្តិនេះនៅពេលក្រោយចុះ ព្រោះមានបញ្ហាផ្សេងទៀតដែលអញចង់និយាយប្រាប់ឯងរាល់គ្នា ។ គឺថាអញដូចជាមិនជឿថា អញនឹងបានរស់នៅជាមួយពួកឯងច្រើនខែតទៅទៀតទេ ។ មុននឹងអញងាប់ទៅ អញមានកាតព្វកិច្ចនឹងរំលែកដល់ពួកឯងនូវគតិបណ្ឌិត ដែលអញបានខំសន្សំទុកមកជាយូរហើយ ។ អញបានរស់មកយូរហើយ ហើយអញក៏បានប្រើពេលច្រើនសម្រាប់គិតតែម្នាក់ឯងទៀតផង ។ ភ្លូវអញដឹងថាអញបានយល់ច្បាស់អំពីន័យនៃជីវិតក្នុងលោកយើងនេះដូចជាសត្វខ្លះដទៃទៀតដែរ ។ គឺគោលគំនិតនេះហើយដែលអញចង់និយាយប្រាប់ពួកឯង ។

សមមិត្ត! តើស្អីទៅដែលហៅថាជីវិត? និយាយឱ្យត្រង់ទៅ ជីវិតគឺសេចក្តីវេទនា សេចក្តីនឿយហត់ ហើយជីវិតគឺការឆាប់ស្លាប់ ។ យើងកើតមកហើយរស់ដោយសារចំណីដែលគេបំប៉នយើងគ្រាន់តែឱ្យមានដង្ហើមចេញចូលតែប៉ុណ្ណោះ ។ អ្នកដែលមានកម្លាំងពលំ ក៏ត្រូវគេយកទៅប្រើរហូតទាល់តែប្រើលែងកើត ។ ហើយក្នុងពេលដែលយើងឈប់បំរើគេកើត គេយកយើងទៅសំឡេះចោលដោយកាចសាហាវបំផុត ។ គ្មានសត្វណាមួយឡើយនៅស្រុក "សង្រែង" យើងនេះ ដែលធ្លាប់បានស្គាល់រសជាតិនៃសុភមង្គល ឬ សេចក្តីត្រេក

សប្បាយក្រោយពីបានអាយុ១ឆ្នាំនោះ ។ គ្មានសត្វណាមួយឡើយ ដែលមានសេរីភាព ។ ជីវិតនៃពួកយើងគឺសេចក្ដីវេទនានិងទាសភាព ។ ទាំងអស់នេះគឺសេចក្ដីពិត ។

តើនេះគ្រាន់តែជាច្បាប់នៃធម្មជាតិប៉ុណ្ណោះ ឬ អី ? តើស្រុកយើងនេះវាក្រពេកទៅឬ រហូតដល់ទៅមិនអាចឱ្យប្រជារាស្ត្រទាំងអស់បានទទួលសេចក្ដីសម្បូរណ៍សប្បាយ ? មិនមែនទេសមមិត្ត! វាមិនពិតទាល់តែសោះ! ដីស្រុកសម្រែងនេះមានដីល្អណាស់ ឯអាកាសធាតុទៀតសោតក៏ល្អដែរល្មមតែអាចអោយផ្ដល់ផលិតផល សម្រាប់ចិញ្ចឹមចំនួនសត្វបានច្រើនជាងនេះទៅទៀត ។ គ្រាន់តែភូមិយើងនេះវាអាចចិញ្ចឹមបានថែមទៀតនូវសេះប្រហែល១ឡូ គោប្រហែល២០ ចៀមប្រហែល១០០ ឱ្យរស់បានយ៉ាងសម្បូណ៌សប្បាយនិងថ្លៃថ្នូរហួសពីយើងស្រមៃទៅទៀត ។ តែហេតុដូចម្ដេចបានជាយើងនៅមានជីវិតក្នុងសភាពដ៏វេទនាបៀបនេះតទៅទៀត? ព្រោះផលិតផលដែលយើងរកបានមកដោយកម្លាំងយើងផ្ទាល់ត្រូវពួកមនុស្សប្លន់យកស្ទើរតែទាំងអស់ ។

នេះហើយសមមិត្ត ដែលជាចំណុចធំនៃចំណោទយើង ។ វាអាចរួមមកតែក្នុងពាក្យមួយម៉ាត់គឺ ' មនុស្ស" ។ មនុស្សជាសត្រូវពិតរបស់យើង ។ ដេញវាចោលទៅ! ហើយដើម



ហេតុនៃសេចក្ដីស្រេកឃ្លាន និងការធ្វើការច្រើនវានឹងរលត់ទៅឯង ។

មនុស្សជាសត្វដែលចេះតែស៊ីតែមិនចេះ បង្កើតផល។ វាមិនចេះបង្កើតទឹកដោះគោឬពងមាន់ទេ ។ វាគ្មានកម្លាំងភ្ជួរស្រែឬរត់ដេញចាប់ទន្សាយទេ ។ ក៏ប៉ុន្តែវាជាម្ចាស់នៃសត្វទាំងឡាយ ។ វាប្រើយើង តែវាឱ្យមកយើងវិញតិចតួចល្មមគ្រាន់តែមិនឱ្យយើងស្លាប់ប៉ុណ្ណោះ ។ នៅសល់ប៉ុន្មានវាយកទុកសម្រាប់ខ្លួនវាទាំងអស់ ។ វាបង្ខំឱ្យយើងធ្វើស្រែឱ្យវា វាយកអាចម៍យើងធ្វើជាជី ក៏ប៉ុន្តែគ្មានសត្វណាមួយដែលមានសម្បត្តិលើសពីស្បែកស្រោបខ្លួនឯងប៉ុណ្ណឹងឡើយ ។

នែអាសម្លាញ់គោ ដែលនៅមុខអញនេះ តើឯងបានឱ្យទឹកដោះឯងដល់មនុស្សប៉ុន្មានពាន់លីត្រហើយ កាលពីឆ្នាំទៅមិញ ? តើទឹកដោះដែលត្រូវតែទុកសម្រាប់ចិញ្ចឹមកូនគោយើងវាទៅឯណាអស់ ? អាទឹកដោះគោទាំងនោះវាបានហូរចូលទៅឯក្នុងបំពង់កសត្រូវរបស់យើងទៅវិញ ។

ចុះចំណែកអាសម្លាញ់មាន់ តើម្ល៉ោងបានពងប៉ុន្មានហើយកាលពីឆ្នាំទៅ ? ហើយតើពងប៉ុន្មានហើយដែលបានត្រូវគេយកទៅភ្ញាស់នៅផ្ទះបាយ ? ហើយប៉ុន្មានដែលគេយកទៅលក់ឯផ្សារដើម្បីប្ដូរជាប្រាក់សម្រាប់ឱ្យអាស្មិតនិងគ្នីគ្នាវា ?

ចុះចំណែក មី កណ្តូបសេះ កូនទាំងបួនរបស់ឯងវាទៅណាហើយ? វាគួរតែបម្រើឯងដល់ឯងចាស់ទៅ ។ អាស្ទិតបានយកទៅលក់អស់ក្នុងពេលដែលវាអាយុបាន១ឆ្នាំ ។ ឥឡូវឯងគ្មានសំណាងនឹងបានជួបមុខវាទៀតឡើយ ។ តើបំណាច់អ្វីខ្លះ ដែលឯងត្រូវបានក្រោយពីបានបង្កើតកូនឲ្យវាបួនក្បាល ហើយខិតខំធ្វើស្រែឲ្យវា ក្រៅពីចំណីក្រៀមក្រោះនិងក្រោលដេករបស់ឯង? ។

ប៉ុន្តែថ្វីបើយើងវេទនាយ៉ាងនេះក៏ដោយ ក៏យើងចេះតែខំអត់ទ្រាំ ។ ដូចជារូបអញជាដើម អញមិនដែលថ្ងូរមួយហ៊ឺះទេ ។ ទុកដូចជាអញមានសំណាងមួយរូបទៅចុះ ។ អញឥឡូវមានអាយុ ១២ ឆ្នាំទៅហើយ ។ រហូតមកដល់ពេលនេះអញបានបង្កើតកូនបានជាង ៤០០ ហើយ ។ នេះជាជីវិតធម្មតារបស់ជ្រូក ប៉ុន្តែគ្មានសត្វណាអាចគេចផុតពីចុងកាំបិតដ៏សាហាវបានឡើយ នៅចុងផាកជីវិតរបស់គេ ។ នែអាកូនជ្រូកទាំងឡាយ វែហ្គងមុខជាត្រូវទ្រហោយំក្នុងរយៈពេលមួយឆ្នាំខាងមុខនេះមិនខាន ។ យើងទាំងអស់គ្នា គោ ជ្រូក មាន់ ចៀម ត្រូវជួបនឹងសេចក្តីវិនាសនោះគ្រប់ ៗ គ្នា ។ សូម្បីតែសេះនិងឆ្កែក៏ចៀសមិនផុតដែរ ។ នែអាព្រូញ ក្នុងពេលដែល វែហ្គងធ្វើការលែងកើត អាស្ទិតវានឹងយកវែហ្គងទៅលក់ឲ្យចិន ។



វែហ្គងនឹងត្រូវគេអារក សម្លាប់ដើម្បីយកស្បែកនិងសាច់ស្ងោរឲ្យឆ្កែស៊ី ។ ឯអាសម្លាញ់ឆ្កែ ដល់ពេលវែហ្គងចាស់ហើយបាក់ធ្មេញអស់ អាស្ទិតនឹងយកថ្មចងជាប់នឹងករឯងហើយយកទៅទម្លាក់ទឹកចោល ។

តើច្បាស់ហើយឬនៅសមមិត្ត ថាសេចក្តីទុក្ខវេទនានៃជីវិតរបស់យើងវាបណ្តាលមកអំពីអំពើកំណាចរបស់មនុស្ស? សម្លាប់វាទៅ ! ដើម្បីឲ្យផលិតផលដែលកើតពីកម្លាំងយើងបានជាសម្បត្តិរបស់យើង ។ ក្នុងពេលមិនយូរទេ យើងនឹងបានសប្បាយព្រមទាំងមានសេរីភាពផង ។

តើយើងត្រូវធ្វើយ៉ាងណា? គឺយើងត្រូវធ្វើការទាំងយប់ទាំងថ្ងៃប្រមូលកម្លាំងកាយ កម្លាំងចិត្ត ដើម្បីរំលំអាពូជមនុស្សនេះ !

នេះហើយជាសាររបស់អញ គឺ បដិវត្តន៍ !

អញមិនដឹងថា តើកាលណាបដិវត្តន៍ នោះនឹងមកដល់ទេ តែវាអាចកើតមានឡើងក្នុងមួយអាទិត្យទៀត ឬ មួយរយឆ្នាំទៀត !

តែអ្វីដែលអញមិនច្រឡំ ហើយឃើញច្បាស់ ដូចអញឃើញស្លឹកស្បូវនៅក្រោមជើងអញនេះ គឺថាមិនយូរមិនឆាប់យុត្តិធមិនឹងឈ្នះអយុត្តិធមិ ។ ចូរសង្ឃឹមហើយចាំចុះសមមិត្ត!